វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សន្ទេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១២ លេខ ០១

## ជំរុញកំណើនប្រកបដោយចីរភាពក្នុងបរិយាកាសសេដ្ឋកិច្ចសាកល កំពុងផ្លាស់ប្តូរៈ ប្រទេសកម្ពុជា ឆ្នាំ២០១២[១]

“ កម្ពុជា និងតំបន់ គឺមានការផ្លាស់ប្តូរយ៉ាងច្រើន ។ ជាក់ស្តែងនាពេលបច្ចុប្បន្ន តំបន់អាស៊ីបានក្លាយជាមជ្ឈមណ្ឌលនៃសេដ្ឋកិច្ចពិភពលោក ដោយអាស៊ីបូព៌ា និងអាស៊ាន គឺជាស្នូលដឹកនាំកំណើនដ៏សំខាន់ និង វិបុលភាពសេដ្ឋកិច្ចពិភពលោក ។”

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ ផ្តល់នូវទស្សនវិស័យដ៏វិជ្ជមានបំផុតក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ស្តីពី ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងសក្តានុពលរបស់កម្ពុជាសម្រាប់ការអភិវឌ្ឍទៅអនាគត ហើយបានគូសរំលេចពីវិស័យដ៏សំខាន់ៗបំផុតដែលរដ្ឋាភិបាល និងវិស័យឯកជនត្រូវដោះស្រាយ ប្រសិនបើចង់ប្រែក្លាយសក្តានុពលដែលមាន ឲ្យទៅជាការពិត ។

កម្ពុជាចាប់ដំណើរការសេដ្ឋកិច្ចនៅឆ្នាំ២០១២ ក្នុងស្ថានភាពមាំមួនគួរឲ្យជឿជាក់ ។ មូលនិធិ រូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករណ៍ថា ផសស កម្ពុជា នឹងមានកំណើន ៦,៥% នៅឆ្នាំ២០១២ ដែលបង្ហាញពីកំណើនភាពជឿជាក់លើសេដ្ឋកិច្ច ក្រោយពេលងើបពីវិបត្តិឆ្នាំ២០០៨-០៩ ។ សម្រាប់រយៈពេលមធ្យម គេប្រមើលឃើញអត្រាកំណើននៅតែមាំមួនរហូតដល់ ៦ ទៅ ៧% ។

នៅឆ្នាំ២០១២ កម្ពុជាដល់វេណធ្វើប្រធានអាស៊ាន ដែលជាឱកាសដ៏មានតម្លៃមួយ ដើម្បីជំរុញទស្សនៈរបស់ខ្លួនចង់ឲ្យមានកំណើនក្នុងតំបន់ប្រកបដោយសមធម៌ និងភាពចុះសម្រុងគ្នាល្អ ។ ប៉ុន្តែក្នុងការកាច់ចង្កូតនាវាអាស៊ាននេះ កម្ពុជាត្រូវឆ្លងកាត់កន្លែងលំបាកស្មុគស្មាញជាច្រើន ពីព្រោះរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចសាកល នៅតែមានគ្រោះថ្នាក់ពិតៗសម្រាប់អាស៊ី ។

### អាស៊ី និងសេដ្ឋកិច្ចសាកល

កំណើន ផសស សាកល ក្នុងឆ្នាំ២០១១ នៅតែយឺតៗ និងគ្មានតុល្យភាព ។ IMF បានកែតម្រូវការព្យាករណ៍កំណើនសាកលមកត្រឹម ៤,៣% វិញ ដោយសារជាសំខាន់ការរើបសេដ្ឋកិច្ចយ៉ាងខ្សោយក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ។

តំបន់អឺរ៉ូ មានស្ថានភាពទន់ខ្សោយជាពិសេស ។ ហានិភ័យនៃបំណុលរដ្ឋនៅប្រទេសក្រិច អ៊ីតាលី និងប្រទេសផ្សេងទៀត ក៏ដូចជាអនុបាតបំណុលកម្រិតខ្ពស់នៅក្នុងតំបន់ បានបង្កជាអស្ថិរភាព និងភាពមិនប្រាកដប្រជា ។

កន្លងមក ការឆ្លើយតបជាគោលនយោបាយ នៅមិនទាន់គ្រប់គ្រាន់ គ្មានការសម្របសម្រួល ហើយត្រូវបរាជ័យក្នុងការកែសម្រួលស្ថានភាព និងផ្តល់លទ្ធភាព ឲ្យធនាគារកសាងមូលធនឡើងវិញ ។ គេផ្តោតជាសំខាន់ទៅលើការកាត់បន្ថយចំណាយ ប៉ុន្តែការរឹតត្បិតចំណាយតែម៉្យាងមិនអាចបានជោគជ័យទេ ពីព្រោះកំណើនសដ្ឋកិច្ច និងការចែករំលែកបន្ទុកជួយរែកពុនគ្នាក្នុងចំណោមបណ្តាប្រទេសនៅអឺរ៉ុប គឺជាកត្តាចាំបាច់ ប្រសិនបើអឺរ៉ុបចង់ងើបឲ្យផុតពីវិបត្តិបច្ចុប្បន្ន ។ គួរឲ្យត្រេកអរដែរ ដែលមហន្តរាយធ្ងន់ធ្ងរមិនទំនងជាកើតមានទេ ប៉ុន្តែគេរំពឹងថានឹងមានការរៀបចំរចនាសម្ព័ន្ធស៊ីជម្រៅឡើងវិញក្នុងទូទាំងតំបន់អឺរ៉ូ ក្នុងពីរបីឆ្នាំខាងមុខនេះ ។

នៅត្រើយម្ខាងទៀតនៃមហាសមុទ្រអាត្លង់ទិច ការរើបសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកមិនទាន់បានច្បាស់លាស់សោះ៖ វិស័យសំណង់ និងវិស័យផ្ទះសម្បែង/កន្លែងការស្នាក់នៅ ជាកត្តាគន្លឹះសម្រាប់ការងើបឡើងវិញ ក្នុងប៉ុន្មានឆ្នាំខាងមុខ ប៉ុន្តែនាបច្ចុប្បន្ន ម្ចាស់ផ្ទះម្នាក់ក្នុងចំណោមប្រាំនាក់ កំពុងជាប់បំណុល ដែលធ្វើឲ្យថយចុះអត្រាចំណាយប្រើប្រាស់ ។ ទីផ្សារពលកម្មចុះខ្សោយ ធ្វើឲ្យនិន្នាការនេះរឹតតែធ្ងន់ធ្ងរថែមទៀត ។ កន្លងមករដ្ឋាភិបាលមិនទាន់មានវិធានការម៉ឺងម៉ាត់ដើម្បីដោះស្រាយបញ្ហានេះទេ ហើយគោលនយោបាយហិរញ្ញវត្ថុ ក៏នៅតែជាប់ផុងមិនដឹងថាត្រូវបង្កើន ឬត្រូវរឹតត្បិតចំណាយ ។

---

១ អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ បកស្រាយដោយឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ លោក Faisal Ahmad តំណាងជាន់ខ្ពស់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំនៅកម្ពុជា លោក Aninda Mitra ប្រធានផ្នែកសេដ្ឋកិច្ចប្រចាំតំបន់អាស៊ីអាគ្នេយ៍ នៃធនាគារ ANZ Royal និងការដកស្រង់ពីសុន្ទរកថាបើកសន្និសីទរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ។

* ផលិតផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១២:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

ស្ថានភាពយ៉ាប់យ៉ឺននៅសហរដ្ឋអាមេរិក និងអឺរ៉ុប អាចបង្កបញ្ហាដល់សេដ្ឋកិច្ចសាកលដែលកាន់តែជាប់ទាក់ទងគ្នាខ្លាំងឡើង។ ដោយឡែកតំបន់អាស៊ីត្រូវពឹងផ្អែកលើតម្រូវការពីខាងក្រៅ ពិសេសពីអ្នកប្រើប្រាស់នៅសហរដ្ឋអាមេរិក និងអឺរ៉ុប។ ការរីករាលដាលវិបត្តិហិរញ្ញវត្ថុពីសហរដ្ឋអាមេរិក និងអឺរ៉ុប ដែលឆ្លងតាមការពាក់ព័ន្ធនឹងទីផ្សារមូលធន ជាពិសេសទីផ្សារសញ្ញាប័ណ្ណ ក៏អាចកើតមានដែរ។

ដំណឹងល្អសម្រាប់អាស៊ី គឺសេដ្ឋកិច្ចប្រទេសអាស៊ីភាគច្រើនមានលក្ខណៈរឹងមាំ ហើយទំនងអាចទប់ទល់នឹងការរីករាលដាលនេះបាន។ អាស៊ីបានចំណាយពេល ក្នុងទសវត្សរ៍ចុងក្រោយនេះ ដើម្បីពង្រឹងមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន បន្ទាប់ពីជួបវិបត្តិឆ្នាំ១៩៩៧។ នាបច្ចុប្បន្នតារាងតុល្យការមានស្ថានភាពល្អ កំណែទម្រង់វិស័យហិរញ្ញវត្ថុ ក៏បានកាត់បន្ថយហានិភ័យតាមរយៈការកាត់បន្ថយបំណុលរដ្ឋាភិបាល និងបំណុលឯកជន។

អន្តរាគមន៍ជាគោលនយោបាយដ៏ម៉ឺងម៉ាត់ក្នុងទូទាំងតំបន់ គឺសំខាន់បំផុតដើម្បីកាត់បន្ថយភាពអត់ការងារធ្វើ និងគ្រប់គ្រងអតិផរណា ព្រមទាំងផ្តល់ជាមធ្យោបាយជំរុញកំណើនតម្រូវការក្នុងស្រុក ប្រសិនបើតម្រូវការពីប្រទេសជឿនលឿនបន្តធ្លាក់ចុះ។

អាស៊ី ក៏មានកំណើនលំហូរចូលមូលធនយ៉ាងច្បាស់ដែរ ដែលជាលទ្ធផលនៃការបង្កើតទុនបម្រុងជាសាច់ប្រាក់របស់អឺរ៉ុប និងកេរ្តិ៍ឈ្មោះអាស៊ីថាជាកន្លែងមានសុវត្ថិភាពសម្រាប់វិនិយោគ។ ប៉ុន្តែនៅមានភាពមិនប្រាកដប្រជាខ្លះអំពីចីរភាពរយៈពេលវែងនៃលំហូរចូលទាំងនេះ ដែលអាចបាត់ទៅវិញយ៉ាងលឿនប្រសិនបើលក្ខខណ្ឌផ្លាស់ប្តូរ។ ក្តីបារម្ភមួយទៀត គឺលំហូរចូលមូលធន ព្រមគ្នានឹងការឡើងថ្លៃទំនិញប្រើប្រាស់នឹងធ្វើឲ្យកើនសម្ពាធអតិផរណា។

និន្នាការកំពុងផុសឡើងនៅអាស៊ី គឺចលនាកាត់បន្ថយភាពពឹងផ្អែកទៅលើតំបន់អឺរ៉ុប និងសហរដ្ឋអាមេរិក ហើយកសាងអនាគតមួយដែលយកប្រទេសខ្លាំងៗក្នុងតំបន់ធ្វើជាក្បាលម៉ាស៊ីនជំរុញកំណើន។

ប្រទេសចិនបានលេចធ្លោជាស្រេចថាជា កម្លាំងដ៏សំខាន់មួយមានសេដ្ឋកិច្ចខ្លាំងក្លា។ ការនាំចេញរបស់ចិនទៅសហរដ្ឋអាមេរិក បានកើនឡើងវិញ រីឯអតិផរណាក៏ហាក់ដូចជាបានកើនអស់កម្រិត និងមានស្ថិរភាពត្រឹមនោះ ហើយចំណុចសំខាន់បំផុត គឺតម្រូវការក្នុងស្រុកជាពិសេសសម្រាប់ទំនិញអន្តរការី កំពុងកើនឡើង។ ពាណិជ្ជកម្មផ្ទៃក្នុងតំបន់អាស៊ី បានរងឥទ្ធិពលយ៉ាងខ្លាំងជាស្រេចពីកំណើនចំណាយប្រើប្រាស់នៅចិន ពីព្រោះបើគិតក្នុងកំណើនមួយឯកតាភាគរយដូចគ្នាចំណាយនេះមានឥទ្ធិពលប្រហែលគ្នានឹង និន្នាការប្រែប្រួលចំណាយប្រើប្រាស់នៅសហរដ្ឋអាមេរិកដែរ។

## ការឈានឡើងរបស់កម្ពុជា

ដូចគ្នានឹងជោគវាសនានៃតំបន់អាស៊ី កម្ពុជាបានរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងទសវត្សរ៍កន្លងទៅនេះ មួយផ្នែកធំដោយសារមានរដ្ឋាភិបាលមានស្ថិរភាពល្អ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រយ័ត្នប្រយែងការកសាងក្របខ័ណ្ឌគោលនយោបាយនិងបទបញ្ញត្តិ និងកិច្ចប្រឹងប្រែងជាប់រហូតក្នុងការបង្កើនសមត្ថភាពស្ថាប័ន។ នៅពេលឡើងធ្វើជាប្រធានអាស៊ាននៅឆ្នាំនេះ កម្ពុជាបានផ្លាស់ប្តូរស្ទើរមើលមិនស្គាល់ បើធៀបនឹងឆ្នាំ២០០២ នៅពេលដែលរាជរដ្ឋាភិបាលដល់វេណធ្វើជាប្រធានអាស៊ានដែរ។

សូចនាករម៉ាក្រូសេដ្ឋកិច្ច បានបង្ហាញពីអនាគតប្រកបដោយស្ថិរភាពមួយ (តារាង ១)។ អតិផរណាមានកម្រិត ៥,៥% នៅឆ្នាំ២០១១ ហើយធនបម្រុងបរទេស កើនឡើងពី ២,៧ពាន់លានដុល្លារនៅឆ្នាំ២០១០

### តារាង ១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ

| | 2009 | 2010 | 2011 | 2012 |
|---|---|---|---|---|
| ផសស ចារឹក (គិតជាលានដុល្លារ) | 10400 | 11634 | 12937 | 14231 |
| ផសស ពិត (% កំណើន) | 0.1 | 6.0 | 6.9 | 6.5 |
| - កសិកម្ម (ចំណែក) | 33.5 | 33.9 | 34.0 | 33.6 |
| - ឧស្សាហកម្ម (ចំណែក) | 21.7 | 21.9 | 22.6 | 23.1 |
| - សេវាកម្ម (ចំណែក) | 38.8 | 38.3 | 37.8 | 37.7 |
| ផសស ក្នុងមនុស្សម្នាក់ (ដុល្លារ) | 753 | 830 | 909 | 984 |
| អតិផរណា (%) | -0.6 | 4.0 | 5.5 | 5.0 |
| ប្រាក់សន្សំជាតិ (% នៃ ផសស) | 21.1 | 24.7 | 23.0 | 22.8 |
| ចំណូលក្នុងស្រុក | 11.9 | 13.2 | 13.2 | 13.4 |
| ចំណាយថវិកា | 20.5 | 21.3 | 18.2 | 18.5 |
| ឱនភាពសរុប | -6.4 | -8.7 | -6.1 | -6.1 |
| ចំណាយវិនិយោគ | 9.1 | 10.3 | 8.1 | 8.6 |
| វិនិយោគក្នុងស្រុក | 13.3 | 13.9 | 13.9 | 14.1 |
| វិនិយោគឯកជន | 16.4 | 16.2 | 16.2 | 16.2 |

ប្រភព៖ បទបង្ហាញរបស់ ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី១៦ កុម្ភៈ ២០១២។

ដល់ ៣,០ពាន់លានដុល្លារនៅឆ្នាំ២០១១។ ឱនភាពគណនីចរន្ត គេព្យាករណ៍ថា នឹងរួមតូចមកត្រឹម ១១,៩% នៃ ផសស នៅឆ្នាំ២០១១ ហើយដោយសារមានអតិរេកដល់ ១៤៣,២លានដុល្លារ នៅឆ្នាំ២០១០ ជញ្ជីងទូទាត់រំពឹងថាបន្តមានអតិរេកទៀត នៅឆ្នាំ២០១១ ។

ស្ថិរភាព បានហុចផលល្អក្នុងទម្រង់ជាកំណើនវិនិយោគផ្ទាល់ពីបរទេស (FDI) ពី ៥៣៣លានដុល្លារនៅឆ្នាំ២០១០ ដល់ ៦៣២លានដុល្លារនៅឆ្នាំ២០១១។ ផ្នែកហិរញ្ញវត្ថុក៏បន្តរឹងប៉ឹងឡើង ដោយប្រាក់បញ្ញើធនាគារកើនឡើង ១៩% ពី ៤ពាន់ដុល្លារនៅខែធ្នូ ២០១០ ដល់ ៤,៨ពាន់លានដុល្លារនៅខែវិច្ឆិកា ២០១១។ ក្នុងពេលជាមួយគ្នា ឥណទានដល់វិស័យឯកជនកើនឡើង ២៨% ពី ៣,៣ពាន់លានដុល្លារនៅខែធ្នូ ២០១០ ដល់ ៤,២ពាន់លានដុល្លារនៅខែវិច្ឆិកា ២០១១។

វិស័យសំខាន់ៗនៅកម្ពុជា ទំនងជារឹងមាំល្អ។ វិស័យកសិកម្មកើនប្រមាណ ៣,៣% នៅឆ្នាំ២០១១ គឺកើនខ្លាំង ថ្វីបើទាបបន្តិចជាងកំណើន ៤% នៅឆ្នាំ២០១០ ក្តី។ ផលិតកម្មស្រូវសរុបប៉ាន់ស្មានកើនដល់ ៨,៤លានតោននៅឆ្នាំ២០១១ ធៀបនឹង ៨,២៤លានតោននៅឆ្នាំ២០១០។ ការនាំចេញអង្ករ កើនដល់ ១៧០.០០០តោន ស្មើនឹង ១០៤លានដុល្លារ នៅឆ្នាំ២០១១ ធៀបនឹង ៣៥លានដុល្លារនៅឆ្នាំ២០១០។ កំណើនដ៏ធំនេះ បានដោយសារគំនិតផ្តួចផ្តើម "អ្វីទាំងអស់ ក្រៅពីអាវុធ" របស់អឺរ៉ុប ដែលនាំឲ្យមានការលើកលែងពន្ធនាំចូល។

ការនាំចេញកៅស៊ូ កើន ១២៥% ដល់ ២០០,៦លានដុល្លារ (៤៦.១០០តោន) នៅឆ្នាំ២០១១ ធៀបនឹង ៣៤,៧លានដុល្លារ (២៣.៨០០តោន) នៅឆ្នាំ២០១០ ដែលឆ្លុះបញ្ចាំងពីកំណើនតម្រូវការកៅស៊ូសម្រាប់ផលិតកង់រថយន្ត ជាពិសេសតម្រូវការពីតំបន់អាស៊ី។

វិស័យឧស្សាហកម្ម កើន ១៤,៣% នៅឆ្នាំ២០១១ ធៀបនឹងកំណើន -៩,៥% នៅឆ្នាំ២០០៩ និង ១៣,៦% នៅឆ្នាំ២០១០។ វិស័យកាត់ដេរមានដំណើរការល្អណាស់ ដោយការនាំចេញកើន ៣០,៧% ពី ៣,០ពាន់លានដុល្លារនៅឆ្នាំ២០១០ ដល់ ៣,៩ពាន់លានដុល្លារនៅឆ្នាំ២០១១។ វិស័យឧស្សាហកម្ម រំពឹងថានឹងកើនឡើងនៅឆ្នាំ២០១២ ហើយការនាំចេញវាយនភ័ណ្ឌ គេព្យាករណ៍ថានឹងបន្តកើនឡើង ហើយ

## រូបភាព ១៖ ការប្រមូលចំណូល




ប្រភព៖ បទបង្ហាញរបស់ ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី១៦ កុម្ភៈ ២០១២។

ទាំងនេះក៏ជាលទ្ធផលនៃគំនិតផ្តួចផ្តើម "អ្វីទាំងអស់ ក្រៅពីអាវុធ" ផងដែរ។

វិស័យសេវាកម្ម កើនដល់ ៥% នៃ ផសស នៅឆ្នាំ២០១១ ដោយសារលទ្ធផលល្អនៃវិស័យទេសចរណ៍។ ចំនួនទេសចរមកដល់កម្ពុជា កើន ១៥% នៅឆ្នាំ២០១១ ដល់ប្រមាណ ២,៨៨លាននាក់។ វិស័យនេះ គេព្យាករណ៍ថានឹងកើនប្រមាណ ៥,៧% នៅឆ្នាំ២០១២ ដែលភាគច្រើនបានពីកំណើនចំនួនភ្ញៀវមកពីតំបន់អាស៊ី។

បច្ចុប្បន្ន មានសញ្ញាជាច្រើនបង្ហាញថា វិស័យអចលនទ្រព្យកំពុងចាប់ផ្តើមងើបឡើងវិញ។ គម្រោងសាងសង់គិតជាតម្លៃទ្រព្យជាប់លាប់អនុម័តដោយរដ្ឋាភិបាល កើនឡើងនៅឆ្នាំ២០១១ ដោយមានប្រមាណ ១៩៨០គម្រោង ស្មើនឹង ១,៦ពាន់លានដុល្លារ ត្រូវបានអនុម័ត ធៀបនឹង ២០០០គម្រោង ស្មើនឹង ៦៥៥លានដុល្លារ នៅឆ្នាំ២០១០ ហើយការនាំចូលសម្ភារៈសំណង់ កើនមួយជាពីរ ដល់ ៥៦០លានដុល្លារ។

រដ្ឋាភិបាលក៏ឈានទៅមុខបានច្រើនដែរ ក្នុងការបង្កើនប្រភពហិរញ្ញវត្ថុ តាមការកែលំអការប្រមូលចំណូល (រូបភាព ១)។ នៅឆ្នាំ២០១១ ការប្រមូលចំណូលក្នុងស្រុកបានលទ្ធផលល្អ និងរំពឹងថាបានល្អដូចឆ្នាំ២០១០ គឺស្មើនឹង ១៣,២% នៃ ផសស។ ការប្រមូលចំណូលដោយអគ្គនាយកដ្ឋានពន្ធដារ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយកើនបាន ១២% ដល់ ២៣៣០ពាន់លានរៀល (៥៧៥លានដុល្លារ) នៅឆ្នាំ២០១១។

## អាទិភាពផ្នែកគោលនយោបាយសម្រាប់អនាគតសេដ្ឋកិច្ចរួមគ្នា

ច្បាស់ហើយ សេដ្ឋកិច្ចកម្ពុជាបានកសាងនៅលើមូលដ្ឋានរឹងមាំ ប៉ុន្តែដោយសារចលនាផ្លាស់ប្តូរសន្ទុះសេដ្ឋកិច្ចក្នុងតំបន់ និងសាកល កម្ពុជាត្រូវតែសម្របខ្លួនតាម បើសិនចង់រីកចម្រើន។

វិធានការផ្នែកគោលនយោបាយជាប់ទាក់ទងគ្នាចំនួនបួន ត្រូវតែអនុវត្តឲ្យបាន ដើម្បីធានាឲ្យសេដ្ឋកិច្ចកម្ពុជាមានចីរភាពទៅអនាគត៖ (១) សមាហរណកម្មក្នុងតំបន់កាន់តែស៊ីជម្រៅ ដែលចាំបាច់បំផុត ដើម្បីបង្កើនពាណិជ្ជកម្ម និងវិនិយោគ ក្នុងបរិបទមានតម្រូវការចុះខ្សោយពីប្រទេសជឿនលឿន តែកើនឡើងពីអាស៊ី (២) ពិពិធកម្មសេដ្ឋកិច្ច ដើម្បីឲ្យសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈត្រៀមស្រេចបាច់ សម្រាប់ទាញយកអត្ថប្រយោជន៍ពីអាស៊ីដែលកំពុងរីកលូតលាស់ (៣) ការបង្កើនផលិតភាពក្នុងគ្រប់វិស័យ ដើម្បីទាញផលចំណេញពីសមាហរណកម្ម និងពិពិធកម្ម និង (៤) ការអភិវឌ្ឍសម្រាប់គ្រប់គ្នា (inclusive development) ដែលមិនត្រឹមតែជាកាតព្វកិច្ចផ្នែកសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាលក្ខណៈសំខាន់បំផុតមួយនៃសេដ្ឋកិច្ចដ៏រឹងមាំ និងមានស្ថិរភាពដែរ។

ការពង្រឹងពង្រីកសមាហរណកម្មភាពតភ្ជាប់គ្នាចុះឡើង គឺជាអាទិភាពមួយសម្រាប់រដ្ឋាភិបាលកម្ពុជា ដែលក្នុងពេលកន្លងមក ក៏បានរួមចំណែកយ៉ាងសកម្មក្នុងអាស៊ាន និងអង្គការឯទៀតក្នុងតំបន់រួចហើយដែរ។

ដោយមានជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា រដ្ឋាភិបាលកម្ពុជាបានប្រើពេលមួយទសវត្សរ៍ចុងក្រោយនេះ ដើម្បីរៀបចំប្រទេសឲ្យស៊ីគ្នានឹងប្រទេសឯទៀតក្នុងតំបន់ ទាំងក្នុងកំណែទម្រង់គោលនយោបាយ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ គួរកត់សម្គាល់ដែរថា គំនិតផ្តួចផ្តើមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់មហាអនុតំបន់មេគង្គ បានផ្តោតលើការកសាងគោលនយោបាយ ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញកំណើនសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាបណ្តាញផ្លូវដែក និងផ្លូវថ្នល់ ការដឹកជញ្ជូន និងបណ្តាញចែកចាយអគ្គិសនី ត្រូវបានកែលំអឡើងទាំងអស់ ដោយលុបបំបាត់របាំងផ្សេងៗរវាងកម្ពុជា ប្រទេសជិតខាង និងទីផ្សារសាកល។

សមាជិកភាពក្នុងអាស៊ាន ជាពិសេសការអនុវត្តផែនទីបង្ហាញផ្លូវសំដៅបង្កើតទីផ្សារតែមួយនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ បានជំរុញឲ្យរដ្ឋាភិបាលធ្វើកំណែទម្រង់គោលនយោបាយដ៏ចាំបាច់ ដើម្បីឲ្យកម្ពុជាបំពេញបានតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរួម។ នៅក្នុងបញ្ជីពិន្ទុសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលកំណត់ជាតួលេខពីកម្រិតដែលប្រទេសជាសមាជិកបានអនុវត្តកំណែទម្រង់ស្ថាប័ន និងបទបញ្ញត្តិច្បាប់ ដើម្បីជួយសម្រួលការធ្វើសមាហរណកម្ម កម្ពុជាសម្រេចបានលើសពី ៧០% នៃលក្ខខណ្ឌសំខាន់ៗដែលតម្រូវឡើង និងជាប់លំដាប់ថ្នាក់លេខ៣ បន្ទាប់ពីសិង្ហបុរី និងម៉ាឡេស៊ី។

កម្ពុជា បានជឿនលឿនទៅមុខច្រើនហើយក្នុងផ្នែកសំខាន់ៗនៃការប្រើប្រព័ន្ធកុំព្យូទ័រដើម្បីគ្រប់គ្រងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងប្រតិបត្តិការគយ ហើយញាំងឲ្យមានការគោរពច្បាប់កាន់តែប្រសើរឡើង។ ប៉ុន្តែនៅមានការងារត្រូវធ្វើជាច្រើនទៀត ដើម្បីពង្រឹងសមត្ថភាពស្ថាប័ននៃទីភ្នាក់ងារដែលទទួលខុសត្រូវលើការគ្រប់គ្រង និងអភិបាលកិច្ចល្អនៃលំហូរប្រជាជន ការដឹកជញ្ជូន និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន។

ការប្រើកម្លាំងពាណិជ្ជកម្ម និងវិនិយោគ ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ចតាមរយៈកំណែទម្រង់ផ្តោតចំគោលដៅ និង/ឬ ពាក់ព័ន្ធច្រើនវិស័យ គឺជាផ្នែកដ៏សំខាន់មួយ នៃយុទ្ធសាស្ត្រសេដ្ឋកិច្ចទូទៅរបស់រដ្ឋាភិបាល។ ពិពិធកម្មសេដ្ឋកិច្ច សំខាន់បំផុត សម្រាប់ចីរភាពសេដ្ឋកិច្ចទៅថ្ងៃអនាគត និងត្រូវផ្សារភ្ជាប់ទៅនឹងសមាហរណកម្មក្នុងតំបន់ ហើយយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល គួរតែឆ្លុះបញ្ចាំងពីស្ថានភាពនេះ ដើម្បីទាញផលចំណេញឲ្យបានច្រើនជាអតិបរមា ព្រមទាំងស្វែងរកភាពជាដៃគូ និងរបៀបវារៈគោលនយោបាយដ៏សមស្របផ្សេងៗក្នុងតំបន់។

នាបច្ចុប្បន្ន កម្ពុជាពឹងផ្អែកខ្លាំងពេកទៅលើការនាំចេញសម្លៀកបំពាក់ ដែលផ្សារភ្ជាប់ជាសំខាន់ទៅនឹងតម្រូវការពីអឺរ៉ុប និងអាមេរិកខាងជើង។ ដូច្នេះ គេចាំបាច់ត្រូវធ្វើពិពិធកម្មសេដ្ឋកិច្ចចូលទៅក្នុងវិស័យថ្មីៗ ដូចជា ការផលិតថាមពល ឧស្សាហកម្មធុនស្រាល និងពង្រីកចូលទៅក្នុងទីផ្សារថ្មីៗ។ សព្វថ្ងៃ គេឃើញមានសញ្ញាខ្លះៗហើយនៃការផុសវិស័យថ្មីៗ

ឡើង ដូចជា ខេត្តក្រចេះដែលកំពុងក្លាយជាមជ្ឈមណ្ឌលដឹកយកមាសជាដើម។ ការអភិវឌ្ឍវិស័យនានាដែលអាចទាញផលចំណេញពីកំណើនតម្រូវការផលិតផលអន្តរការីពីប្រទេសចិន និងការធ្វើសមាហរណកម្មចូលទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ក៏សំខាន់ណាស់ដែរ។

ការធ្វើពិពិធកម្មចូលទៅក្នុងវិស័យថ្មីៗ គួរធ្វើឡើងទន្ទឹមគ្នានឹងការបង្កើនផលិតភាព និងការធ្វើពិពិធកម្មក្នុងវិស័យ ដើម្បីឲ្យមានប្រភេទផលិតផល និងវិធីផលិតថ្មីៗ និងការជ្រៀតចូលទៅក្នុងទីផ្សារថ្មីៗថែមទៀត។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាលត្រូវផ្តោតលើការបង្កើនផលិតភាពក្នុងសេដ្ឋកិច្ចទាំងមូល តាមរយៈគោលនយោបាយផ្តោតចំគោលដៅដែល លុបបំបាត់ឧបសគ្គរាំងកំណើនការនាំចេញតាមវិស័យសំខាន់ៗ និងជំរុញកំណើនវិនិយោគក្នុងវិស័យទាំងនោះ។

ក្នុងវិស័យកសិកម្ម នៅមានធនធានធម្មជាតិ និងសក្តានុពលកំណើនច្រើនណាស់ដែលមិនទាន់បានយកមកប្រើប្រាស់។ ដើម្បីសម្រេចការងារនេះ គោលនយោបាយត្រូវផ្តោតលើការនាំចេញផលិតផលកសិកម្ម ការឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃបន្ថែម និងការជ្រៀតចូលទៅក្នុងទីផ្សារថ្មីៗ។ ក្នុងនេះ គោលនយោបាយពាណិជ្ជកម្មជំរុញកំណើនការនាំចេញស្រូវអង្ករ គឺសំខាន់ខ្លាំងណាស់ ក៏ដូចជា សេវាមីក្រូហិរញ្ញវត្ថុ និងសេវាផ្សព្វផ្សាយបច្ចេកទេសដែលជួយកាត់បន្ថយចំណាយ និងបង្កើនផលិតភាពដីស្រែតូចៗ។

ក្នុងវិស័យកាត់ដេរដោយប្រពៃណី និងវិស័យទេសចរណ៍ ក៏មានផ្នែកដែលគួរធ្វើពិពិធកម្មដែរ។ វិធីផលិតកាន់តែមានប្រសិទ្ធភាព អាចជួយកម្ពុជាឲ្យឈានដល់ផលិតកម្មសម្លៀកបំពាក់មានគុណភាពល្អ និងបានថ្លៃកាន់តែខ្ពស់។ សំខាន់ណាស់ វិស័យឧស្សាហកម្ម ត្រូវឆក់ឲ្យបាននូវឱកាសល្អដែលប្រទេសចិនកំពុងរីកចម្រើន ក្នុងនេះមានទាំងវិនិយោគជាសក្តានុពលពីសំណាក់ផលិតករសម្លៀកបំពាក់នៅចិនផង។ ដោយមានវិស័យកាត់ដេររឹងមាំស្រាប់ និងមានកម្លាំងពលកម្មមានតម្លៃប្រកួតប្រជែង កម្ពុជាអាចទាញយកផលចំណេញពីកំណើនវិនិយោគចិន ក្នុងវិស័យកាត់ដេរនេះ។

វិស័យទេសចរណ៍ អាចធ្វើពិពិធកម្មចេញពីទេសចរណ៍វប្បធម៌ ទៅខាងទេសចរណ៍តំបន់ឆ្នេរ និងអេកូទេសចរណ៍បាន។ ការអភិវឌ្ឍដីកោះនៅប៉ែកខាងត្បូងក្រុងព្រះសីហនុ ផ្តល់ក្តីសង្ឃឹមច្រើន ហើយកន្លងមកបានទាក់ទាញវិនិយោគយ៉ាងច្រើនទាំងក្នុងស្រុក និងបរទេស។

ការសិក្សាស្រាវជ្រាវពីកត្តារាំងស្ទះពិពិធកម្មនៅតាមវិស័យជាក់លាក់នៅមានតិចតួចនៅឡើយ ហើយត្រូវដោះស្រាយតាមការសិក្សាស្រាវជ្រាវម៉ត់ចត់ជាក់ស្តែង រួចផ្តល់ព័ត៌មានសម្រាប់គោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីអាចបំបាត់កត្តារាំងស្ទះប្រកបដោយប្រសិទ្ធភាព នៅពេលវាផុសឡើង។

ក្នុងពេលជាមួយគ្នា គោលនយោបាយពាក់ព័ន្ធច្រើនវិស័យមានមូលដ្ឋានធំទូលាយ ត្រូវតែមានបំពេញបន្ថែមដោយគោលនយោបាយផ្តោតចំគោលដៅជាក់លាក់។ ដោយឡែក បរិយាកាសជំនួញនៅកម្ពុជាត្រូវតែពង្រឹងបន្ថែម ដើម្បីលើកទឹកចិត្តដល់ការវិនិយោគចម្រុះ មានរយៈពេលវែង។ វិធីសាស្រ្តនេះនឹងផ្តល់ប្រយោជន៍យ៉ាងច្រើនដល់សកម្មភាពកសិកម្ម និងឧស្សាហកម្មជាក់ស្តែង ទាំងតូច ទាំងធំ ហើយចែកចាយផលចំណេញដល់គ្រប់ស្រទាប់សង្គម។

បញ្ហាធម្មតាមួយចំនួន ក៏ត្រូវដោះស្រាយដែរ ជាពិសេស សមត្ថភាពស្ថាប័នសម្រាប់ អនុវត្តក្របខ័ណ្ឌគោលនយោបាយ និងបទបញ្ញត្តិច្បាប់កម្ពុជា។ គំនិតផ្តួចផ្តើមក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងបង្កើនសមត្ថភាពស្ថាប័នក្នុងការអនុវត្តច្បាប់ និងគោលនយោបាយ គឺសំខាន់បំផុតដើម្បីបង្កើនវិនិយោគចម្រុះមានរយៈពេលវែង។

កត្តាមួយទៀតដែលរាំងស្ទះពិពិធកម្ម និងកំណើនផលិតភាព ក្នុងវិស័យពាក់ព័ន្ធគ្នាជាច្រើន គឺភាពមិនស៊ីគ្នារវាងជំនាញនៅក្នុងទីផ្សារពលកម្ម និងតម្រូវការរបស់វិស័យឯកជន។ ដូច្នេះ គោលនយោបាយត្រូវលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម (SMEs) និងកៀរគរវិនិយោគ ដើម្បីផ្តល់ការងារដល់យុវជនដែលឈានចូលក្នុងទីផ្សារពលកម្ម។ ដោយមានជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍ កន្លងមកបានធ្វើកំណែទម្រង់ច្រើនហើយ លើស្ថាប័នអប់រំជាន់ខ្ពស់ (HEIs) និងក្នុងការអភិវឌ្ឍផែនការអប់រំ បណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ (TVET) ប៉ុន្តែនៅមានកិច្ចការត្រូវធ្វើជាច្រើនទៀត ដើម្បីធានាឲ្យស្ថាប័នសិក្សាអប់រំឆ្លើយតបបានទៅនឹងតម្រូវការនៃឧស្សាហកម្ម។ កិច្ចសហប្រតិបត្តិការកាន់តែប្រសើររវាងវិស័យសាធារណៈ និងឯកជន ក៏ចាំបាច់ដែរ ក៏ដូចជារបៀបរបបអនុវត្តន៍ល្អៗ ដែលទទួលបានជោគជ័យក្នុងពេលកន្លងមក។

ម៉្យាងទៀត ត្រូវមាននយោបាយសម្រាប់ប្រយុទ្ធប្រឆាំងនឹងវិសមភាពដោយផ្ទាល់ និងលើកកម្ពស់កំណើនសម្រាប់គ្រប់គ្នា។ ជាតុពិតគួរឲ្យបារម្ភមួយ គឺតាំងពីដើមរៀងមក តំបន់អាស៊ីតែងតែមានកំណើនវិសមភាព ទោះបីមានកំណើនសេដ្ឋកិច្ចក្តី។ កម្ពុជាក៏មាននិន្នាការមិនខុសពីនេះដែរ ព្រោះទោះបីមានការកាត់បន្ថយភាពក្រីក្រជាទូទៅក្តី ក៏តួលេខអត្រាកាត់បន្ថយមិនសូវធំទេ។

ការអភិវឌ្ឍគ្មានសមធម៌ អាចប៉ះពាល់មិនល្អទៅលើកំណើនយោងតាមទ្រឹស្តីនៃសេដ្ឋកិច្ចនយោបាយ។ ស្ថិរភាពនយោបាយ និងកំណើនមានសមធម៌ សំខាន់ខ្លាំងណាស់សម្រាប់វិនិយោគ និងការជំរុញស្មារតីសហគ្រិនភាពជាទូទៅ។

ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយសមធម៌ មូលដ្ឋានហិរញ្ញវត្ថុរបស់កម្ពុជា ត្រូវតែពង្រីកបន្ថែម តាមរយៈការកែលំអអត្រាប្រមូលចំណូល។ មូលដ្ឋានហិរញ្ញវត្ថុ ត្រូវមានបំពេញបន្ថែមដោយក្របខ័ណ្ឌគោលនយោបាយផ្សេងៗ ដែលចែកចាយផលចំណេញដល់សង្គមទាំងមូល ជាពិសេសតាមការកែលំអផលិតភាពកសិកម្ម និង SMEs និងតាមការបង្កើតប្រព័ន្ធសុវត្ថិភាពសង្គម ដែលជួយការពារជនក្រីក្រ និងជនងាយរងគ្រោះ ពីវិបត្តិសេដ្ឋកិច្ច។ ម៉្យាងទៀត ការវិនិយោគច្រើនៗក្នុងវិស័យអប់រំ ដែលនឹងហុចផលចំណេញទៅអនាគត ក៏ត្រូវធ្វើជាបន្ទាន់ដែរ។

ការដោះដូរគ្នារវាងកំណើន និងបរិស្ថាន គួរគ្រប់គ្រងយ៉ាងណា ដើម្បីឲ្យកំណើនមិនប៉ះពាល់ដល់ចីរភាពនៃបរិស្ថាន។ ក្នុងនេះ ត្រូវមានការស្រាវជ្រាវពីទិដ្ឋភាពផ្នែកបរិស្ថាននៃការអភិវឌ្ឍនៅកម្ពុជា ដើម្បីធ្វើឲ្យគោលនយោបាយនាពេលអនាគត អាចធានាបាននូវកំណើន និងការរក្សាការពារធនធានក្នុងប្រទេសសម្រាប់មនុស្សជំនាន់ក្រោយ៕

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**
អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh